# Vacancy Announcement

FTB
ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា
Foreign Trade Bank of Cambodia

## ដំណឹងជ្រើសរើសបុគ្គលិកស្ម័គ្រចិត្ត

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា គឺជាធនាគារកម្ពុជាដំបូងគេបំផុតដែលបានផ្តល់នូវភាពជឿទុកចិត្តនិងផ្តល់នូវសុវត្ថិភាពខ្ពស់បំផុតជូនដល់អតិថិជនក្នុងវិស័យធនាគារ អស់រយៈពេលជាង ៣៧ ឆ្នាំមកហើយ។ ជាមួយនឹងការិយាល័យកណ្តាលនៅទីក្រុងភ្នំពេញ បច្ចុប្បន្នភាពយើងបានពង្រីកនិងធ្វើប្រតិបត្តិការ មានចំនួន ១១សាខា នៅទូទាំងទីក្រុងភ្នំពេញ ខេត្តព្រះសីហនុ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកំពង់ចាម និងកំពុងពង្រីកនូវប្រតិបត្តិការរបស់ខ្លួនឆ្ពោះទៅកាន់គោលដៅទីផ្សារផ្សេងៗទៀត។ ស្របតាមការវិវឌ្ឍន៍ និងភាពរីកចម្រើនរបស់ខ្លួន ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា កំពុងមានតម្រូវការ និងស្វែងរកបេក្ខជន ដែលមានលក្ខណសម្បត្តិ និងឆន្ទៈខ្ពស់ដើម្បីចូលរួមជាមួយពួកយើង សម្រាប់មុខងារដូចតទៅ៖

### បុគ្គលិកស្ម័គ្រចិត្ត (ចំនួន ១០ នាក់ បម្រើការរយៈពេល ៣ខែ)

### កិច្ចការចម្បងៗ និងការទទួលខុសត្រូវ

- សិក្សាស្វែងយល់អំពី ផលិតផលសេវាកម្មរបស់ធនាគារ FTB
- ផ្សព្វផ្សាយ និងចែកចាយខិតប័ណ្ណរបស់ធនាគារ តាមទីសាធារណៈ ជាពិសេសតាមភ្នាក់ងារ Wing ក្នុងក្រុងភ្នំពេញ
- ជួយធ្វើការទាញយក (download) និងចុះឈ្មោះលើកម្មវិធី FTB mobile Banking ដល់អតិថិជនទាំងអស់របស់ Wing
- ពន្យល់អំពីលក្ខណៈពិសេស និងអត្ថប្រយោជន៍របស់ mBanking ដល់អតិថិជន
- ណែនាំបង្ហាញដល់អតិថិជនពីរបៀបប្រើប្រាស់ mBanking
- រៀបចំរបាយការណ៍ប្រចាំសប្តាហ៍ដល់អ្នកគ្រប់គ្រង
- បំពេញការងារផ្សេងៗដែលថ្នាក់គ្រប់គ្រងបានដាក់ជូន ។

### លក្ខណសម្បត្តិ និងបទពិសោធន៍

- យ៉ាងតិចបរិញ្ញាបត្រឆ្នាំទី២ ផ្នែកហិរញ្ញវត្ថុ, ធនាគារ, គណនេយ្យ, ទីផ្សារ ឬសញ្ញាបត្រសមមូល
- មានលក្ខណសម្បត្តិក្នុងការប្រាស្រ័យទាក់ទងល្អ រួសរាយ រាក់ទាក់ និងមានឥរិយាបថចេះបម្រើអតិថិជន
- មានភាពស្មោះត្រង់ សុចរិតភាព អត់ធ្មត់ និងសកម្មលើការងារ
- អាចនិយាយ និងសរសេរជាភាសាអង់គ្លេសបានល្អ
- ចេះដោះស្រាយបញ្ហា និងមានភាពទទួលខុសត្រូវខ្ពស់
- យល់ដឹងពីបច្ចេកវិទ្យាព័ត៌មាន និង ការប្រើប្រាស់ Smart Phone

✵ បេក្ខជនមានឱកាសទទួលបានបទពិសោធន៍ និងប្រាក់ឧបត្ថម្ភតាមគោលការណ៍របស់ធនាគារ។

### របៀបដាក់ពាក្យ

កាលបរិច្ឆេទកំណត់ដាក់ពាក្យៈ ផុតកំណត់ឈប់ទទួលពាក្យនៅថ្ងៃទី **១៣** ខែ **ធ្នូ** ឆ្នាំ **២០១៧** វេលាម៉ោង ០៥:០០ រសៀល ។
បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមអញ្ជើញផ្ញើប្រវត្តិរូបសង្ខេប (<u>មានបិទរូបថត</u>) ជាមួយលិខិតអមជាភាសាខ្មែរ/អង់គ្លេសមកធនាគារតាមរយៈអ៊ីម៉ែលៈ hr@ftbbank.com ឬការិយាល័យកណ្តាល ស្ថិតនៅអគារលេខ ៣៣C-D ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ឬតាមសាខាណាមួយ របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ។ បេក្ខជនមានឱកាសទទួលបានការធ្វើតេស្ត សរសេរភ្លាមៗ នៅពេលដាក់ CV ។